# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម

០៣-១២-២០០៩ -ព្រះរាជក្រម នស/រកម/១២០៩/០២៣ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពី ការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និង អាវុធវិទ្យុសកម្ម ៩១៤២

### ២-ព្រះរាជក្រឹត្យ

២៧-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/១០១៩ ស្តីពី ការតែងតាំងឯកឧត្តម **ឈឹម តន** ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី ២ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន និង តែងតាំង ជា ទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី ២ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ចំនួន ០២ រូប ៩១៥៤

២៧-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១១០០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកឧកញ៉ា, និង អស់លោក ចំនួន ២៩ រូប ៩១៥៥

២៧-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១១០១ ស្តីពី ការប្រោសព្រះរាជទាន ចំពោះលោក **តេរូអូ ជីណាយ** (Teruo JINNAI) នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៩១៥៧

២៧-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១១០២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម ចំនួន ០៣ រូប ៩១៥៨

២៧-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១១០៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង អស់លោក ចំនួន ០៩ រូប ៩១៥៩

២៧-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១១០៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង អស់លោក ចំនួន ១៣ រូប ៩១៦០

២៧-១១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១១០៩/១១០៥ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ កងពលតូចទ័ពពិសេសឆ័ត្រយោង លេខ ៩១១ នូវគ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ ៩១៦១

០១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១០៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,ព្រះសង្ឃ,អស់លោក និង លោកស្រី ចំនួន ១២ រូប ៩១៦២

០១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១០៨ ស្តីពី ការដាក់លោកជំទាវ **សុខ ច័ន្ទឆវី** បច្ចុប្បន្ន ជាអគ្គនាយកនៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និង អភិវឌ្ឍសេដ្ឋកិច្ច នៃក្រសួងកិច្ចការនារី ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស រយៈពេល ០១ ឆ្នាំ ៩១៦៣

០១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១០៩ ស្តីពី ការដាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ឱ្យចូលនិវត្តន៍តាមក្របខ័ណ្ឌមុខងារសាធារណៈ ដោយនៅរក្សាតួនាទី និងមុខតំណែងក្នុងក្របខ័ណ្ឌនយោបាយ ចំនួន ០៦ រូប និងដាក់មន្ត្រីរាជការឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ឱ្យចូលនិវត្តន៍តាមក្របខ័ណ្ឌមុខងារសាធារណៈចំនួន ០៣ រូប ៩១៦៥

០១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១១០ ស្តីពី ការតាំងស៊ប់មន្ត្រីរាជការស៊ីវិល ចំនួន ១០ រូប ក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និង មន្ត្រីរាជការស៊ីវិល ចំនួន ០៤ រូប ក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ៩១៦៨

០១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១១១ ស្តីពី ការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ត្រី **ស៊ុន ហួរ** ជាទីប្រឹក្សា អមទីស្តីការគណៈរដ្ឋមន្ត្រី ជួយកិច្ចការរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៩១៧០

០១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១១២ ស្តីពី ការផ្ទេរបញ្ចូលទៅក្នុង ឋានន្តរស័ក្តិ អនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ២២១ នាក់ ៩១៧១

០១-១២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១២០៩/១១១៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ២២ រូប ៩១៧៨

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ

០៣-១២-២០០៩ -អនុក្រឹត្យលេខ ២០៧ អនក្រ.បក ស្តីពី ការផ្តល់ប្រាក់បំណាច់ជីវភាពជូនមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និង ជនពិការនិវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនបាត់បង់សមត្ថភាពពលកម្ម ដែលជាអតីតយុទ្ធជន ៩១៨០

០៣-១២-២០០៩ -អនុក្រឹត្យលេខ ២០៨ អនក្រ.បក ស្តីពី ការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន និង ការបង្កើនបៀវត្សរ៍សុទ្ធសាធរបស់មន្ត្រីរាជការ ៩១៨២

០៧-១២-២០០៩ -អនុក្រឹត្យលេខ ២០៩ អនក្រ.បក ស្តីពី ការផ្ទេរគណទានថវិកា ៩១៨៤

០២-១២-២០០៩ -អនុក្រឹត្យលេខ ១៦៩៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩១៨៦

០២-១២-២០០៩ -អនុក្រឹត្យលេខ ១៦៩៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩១៨៧

០២-១២-២០០៩ -អនុក្រឹត្យលេខ ១៦៩៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩១៩០
០២-១២-២០០៩ -អនុក្រឹត្យលេខ ១៦៩៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩១៩៨
០២-១២-២០០៩ -អនុក្រឹត្យលេខ ១៦៩៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៩១៩៩
០២-១២-២០០៩ -អនុក្រឹត្យលេខ ១៦៩៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩២០០
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧០០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២០១
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧០១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៩២០២
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧០២ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៩២០៣
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧០៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២០៤
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧០៤ អនក្រ.តត ស្តីពី ការផ្ទេរ និង តែងតាំងមន្ត្រីរាជការ ៩២០៥
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧០៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩២០៧
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧០៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩២០៨
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧០៧ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៩២១០
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧០៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩២១១
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧០៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩២១២
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧១០ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ៩២១៣
០៣-១២-២០០៩ -អនុក្រឹត្យលេខ ១៧១១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៩២១៤

## ២-សេចក្តីសម្រេច

០៣-១២-២០០៩ -សេចក្តីសម្រេចលេខ ៧៣ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំមហោស្រពសិល្បៈចម្រៀងខ្មែរជាសកល ៩២១៩
០៨-១២-២០០៩ -សេចក្តីសម្រេចលេខ ៧៤ សសរ ស្តីពី ការរៀបចំ និង សម្របសម្រួល «វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី ៣» ៩២២២
០៩-១២-២០០៩ -សេចក្តីសម្រេចលេខ ៧៥ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៩២២៥

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៩-១១-២០០៩ -ប្រកាសលេខ ១១០៤ ឧរថ.វសក.ប្រក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃ នាយកដ្ឋានព័ត៌មាន ៩២២៦

១៩-១១-២០០៩ -ប្រកាសលេខ ១១០៥ ឧរថ.វសក.ប្រក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃ នាយកដ្ឋានអភិវឌ្ឍស្តង់ដារ បណ្តុះបណ្តាល និង ពិគ្រោះយោបល់ ៩២៣២

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៤-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨០១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ិនធើខេសិន ហ្វូរ ហ៊ែល ៩២៤០

២៤-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨០៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ទ្រីលាន លីមីធីត ៩២៤២

២៤-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨០៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ិនខេសមេន ភី.អេច អិលធីឌី ៩២៤៤

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៣៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ្គោលដេន អារូម៉ា & អាសូស៊ីអេត ៩២៤៦

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៣៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន គង់ ល៉ែន គ្រុប ៩២៤៨

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៣៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ៊ិាលហ្វ័ត ឡូជីស្ទិត (ខេមបូឌា) ៩២៥០

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៣៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន គខ សុចណ្ណ ៩២៥២

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៤១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស៊ីមហ្វូនី តាហ្វេ ៩២៥៤

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៤២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេល ខេម ៩២៥៦

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៤៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេច ខេ ខូរៀ (ខេមបូឌា) ៩២៥៨

២៥-០២-២០០៩ -លិខិតបញ្ជាក់លេខ ០៨៥០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេស.ខេ.ភី. ត្រាវ៉ែល ៩២៦០

# ព្រះរាជក្រម

នស/រកម/១២០៩/០២៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និង អាវុធវិទ្យុសកម្ម

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅហាមឃាត់ជាដាច់ខាតនូវការផលិត ការកែច្នៃ ការទទួល ការផ្ទេរ ការរក្សាទុក ការដឹកជញ្ជូន និងការប្រើប្រាស់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណងធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការពារបរិស្ថាន សុខុមាលភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកការពារសន្តិសុខ និងសន្តិភាពក្នុងតំបន់ និង ពិភពលោក ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពទៅលើ :

- ប្រជាពលរដ្ឋខ្មែរ ទាំងក្នុងនិងទាំងក្រៅប្រទេស
- ជនបរទេសដែលបានចូល ឬ ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ស្ថាប័ន គ្រឹះស្ថានសាធារណៈ មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នៃព្រះរាជាណាចក្រកម្ពុជា
- ក្រុមហ៊ុន ឬ សាជីវកម្ម ឬ នីតិបុគ្គល ដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីមានសាខា ឬ បុត្រសម្ព័ន្ធ នៅក្នុង ឬ ក្រៅប្រទេសក៏ដោយ
- នាវា យន្តហោះ និងរាល់មធ្យោបាយដឹកជញ្ជូន ដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះនៅទីណាក៏ដោយ
- នាវា យន្តហោះ និងរាល់មធ្យោបាយដឹកជញ្ជូន ដែលបានចុះបញ្ជីនៅបរទេស តែធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

១- អាវុធគីមី សំដៅដល់ យុទ្ធោបករណ៍ ផលិតផលសម្រេច ដែលត្រូវបានផលិតឡើងដោយបំពាក់ នូវសារធាតុគីមី រំសេវផ្ទុះ និងក្បាលកឹបផ្ទុះ ។

២- អាវុធនុយក្លេអ៊ែរ សំដៅដល់ :

ក-អាវុធមហាប្រល័យគ្រប់ប្រភេទដែលអំណាចរបស់វាផ្ទុះដោយកម្លាំងបំបែកអាតូម បង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វរុក្ខជាតិ ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

ខ-គ្រឿងផ្ទុះនុយក្លេអ៊ែរ ។

គ-គ្រឿងសម្រាប់សាយភាយវិទ្យុសកម្ម ឬគ្រឿងបញ្ចេញចុណ្ណភាគវិទ្យុសកម្ម ដោយសារសមាសធាតុវិទ្យុសកម្មរបស់វា ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វរុក្ខជាតិ ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

ឃ-ម៉ាស៊ីនប្រតិកម្មនុយក្លេអ៊ែរ សម្រាប់ប្រើជាប្រភពថាមពល ក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វរុក្ខជាតិ ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

ង-សារធាតុនុយក្លេអ៊ែរ ដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វរុក្ខជាតិ ទ្រព្យសម្បត្តិ ឬបរិស្ថាន

ច-ឧបករណ៍ សម្ភារៈ ដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងកែច្នៃ ឬបង្កើតអាវុធនុយក្លេអ៊ែរ ។

៣- អាវុធជីវសាស្ត្រ សំដៅដល់ :

ក-អាវុធមេរោគ ឬភ្នាក់ងារមេរោគ ដែលបង្កើតដោយអតិសុខុមប្រាណត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វរុក្ខជាតិ ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

ខ-ឧបករណ៍ សម្ភារៈ សម្រាប់ប្រើប្រាស់ក្នុងការកែច្នៃ ឬផលិតអាវុធមេរោគ ឬភ្នាក់ងារមេរោគ ដូចមានចែងនៅក្នុងវាក្យខណ្ឌ " ក " ខាងលើ ។

៤- អាវុធវិទ្យុសកម្ម សំដៅដល់ ប្រភពវិទ្យុសកម្មដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងបង្កឱ្យមានគ្រោះ ថ្នាក់ដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬ បរិស្ថាន ។

៥- សារធាតុគីមី សំដៅដល់ :

ក-សារធាតុគីមី ឬ សារធាតុផ្សំទាំងឡាយណា ដែលប្រើសម្រាប់ផលិតអាវុធ ឬ ប្រើជាអាវុធ ក្នុងគោលបំណងបង្កឱ្យ មានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬ បរិស្ថាន ។

ខ-យុទ្ធោបករណ៍ និងបរិធាននានា ដែលគេផលិតសម្រាប់បង្កឱ្យ មានការស្លាប់ ឬ បង្កឱ្យ មានគ្រោះថ្នាក់ដល់មនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬ បរិស្ថាន ដោយសារជាតិពុលនៃសារធាតុគីមី ដែលបានបញ្ចេញដោយសារការប្រើប្រាស់យុទ្ធោបករណ៍ និង បរិធានទាំងនោះ ។

គ- បរិក្ខារទាំងឡាយណាដែលត្រូវបានគ្រោងជាពិសេស សម្រាប់ប្រើផ្ទាល់ជាមួយយុទ្ធោបករណ៍ និង បរិធាន ដែលមានចែងនៅក្នុងវាក្យខណ្ឌ " ខ " ខាងលើ ។

៦- បុគ្គល សំដៅដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលមិនមែនជាស្ថាប័នរដ្ឋ ។

## ជំពូកទី ២
## អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

**មាត្រា ៥.–**

រាជរដ្ឋាភិបាលត្រូវបង្កើតអាជ្ញាធរជាតិមួយធ្វើជាតំណាងរបស់ខ្លួនដែលមានឈ្មោះថា " អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម " ហៅកាត់ថា " អាជ្ញាធរជាតិអាវុធគីមី " ឬ " អ.ជ.អ.គ. " ។

**មាត្រា ៦.–**

អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្មនេះ ត្រូវបង្កើតឡើងដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ការហាមឃាត់

**មាត្រា ៧.-**

ការផលិត ការកែច្នៃ ការទទួល ការផ្ទេរ ការរក្សាទុក ការដឹកជញ្ជូនឆ្លងកាត់ និងការប្រើប្រាស់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ត្រូវហាមឃាត់ដាច់ខាត ។

**មាត្រា ៨.-**

ការផលិត ការកែច្នៃ ការទទួល ការផ្ទេរ ការរក្សាទុក ការដឹកជញ្ជូនឆ្លងកាត់ និងការប្រើប្រាស់សារធាតុគីមី ដែលទាក់ទងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ត្រូវហាមឃាត់ លើកលែងតែសារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ដែលយកទៅប្រើប្រាស់ក្នុងវិស័យសុខាភិបាល ឧស្សាហកម្ម រ៉ែ ថាមពល កសិកម្ម ការស្រាវជ្រាវ និងគោលដៅសន្តិភាពផ្សេងទៀតដែលមានការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ៩.-**

សារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## ការឆែកឆេរ និងការចាប់យកវត្ថុតាង

**មាត្រា ១០.-**

មន្ត្រីអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម មានតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌ ដែលបំពេញភារកិច្ចតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលជាធរមាន ។

**មាត្រា ១១.-**

ការឆែកឆេរនិងការចាប់យកវត្ថុតាងនៅទីកន្លែងដែលសង្ស័យថាមានរក្សាទុកនូវអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ និងមានដីកាតុលាការ មានសិទ្ធិឆែកឆេរគ្រប់ទីកន្លែងដែលសង្ស័យថាមានរក្សាទុកនូវអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម សារធាតុគីមី ដែលអាចផ្សំផលិតជាអាវុធទាំងនោះ ដែលពុំមានលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច និងកាកសំណល់នៃសារធាតុខាងលើ ដែលនៅមានឥទ្ធិពលបង្កមហន្តរាយ ដើម្បីបង្ក្រាបចាប់យកវត្ថុតាង និងឃាត់ខ្លួនជនសង្ស័យប្រព្រឹត្តល្មើស ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២.-**

រាល់វត្ថុតាងដែលចាប់យកបាន ត្រូវរក្សាទុកក្នុងឃ្លាំងសុវត្ថិភាពដែលគ្រប់គ្រងដោយអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ដើម្បីចាត់ចែងបែបបទធ្វើការបំផ្លាញចោល ឬ រក្សាទុកសម្រាប់ប្រើប្រាស់ក្នុងវិស័យសុខាភិបាល ឧស្សាហកម្ម រ៉ែ ថាមពល កសិកម្ម ការស្រាវជ្រាវ និង គោលដៅសន្តិភាពផ្សេងទៀត ។

## ជំពូកទី ៥
## ការបំផ្លាញ

**មាត្រា ១៣.-**

រាជរដ្ឋាភិបាលត្រូវបង្កើតឱ្យមានគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំនីតិវិធីបំផ្លាញចោលនូវអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារ-ធាតុគីមីដែលបានហាមឃាត់ទៅតាមបទដ្ឋានបច្ចេកទេស ។

**មាត្រា ១៤.-**

ក្នុងករណីចាំបាច់ នៅរាល់ការបំផ្លាញអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ រាជរដ្ឋាភិបាល

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

8/13

Kh

អាចស្នើសុំអ្នកជំនាញបច្ចេកទេសពីអង្គការជាតិ និង អន្តរជាតិ ។

**មាត្រា ១៥.-**

រាល់វិធានការបំផ្លាញ ដូចមានចែងនៅក្នុងមាត្រា១៣ និង មាត្រា១៤ នៃច្បាប់នេះ ត្រូវគោរពគោលការណ៍សុវត្ថិភាព សន្តិសុខ និងបរិស្ថាន ។

## ជំពូកទី ៦
## គោលនយោបាយ និងផែនការសកម្មភាព

**មាត្រា ១៦.-**

អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និង វិទ្យុសកម្ម ត្រូវរៀបចំគោលនយោបាយ និងផែនការសកម្មភាព ទាក់ទងនឹងការហាមឃាត់និងទប់ស្កាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមី ដែលអាចផ្សំសម្រាប់ផលិតអាវុធទាំងនេះ ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល អង្គការជាតិ និងអន្តរជាតិនានា ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**មាត្រា ១៧.-**

រាល់គោលនយោបាយ និងផែនការសកម្មភាព ត្រូវធានាថានៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គ្មានអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងគ្មានសារធាតុគីមីដែលបានហាមឃាត់ ។

## ជំពូកទី ៧
## ការអប់រំ និងការផ្សព្វផ្សាយ

**មាត្រា ១៨.-**

អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ត្រូវធ្វើការអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ ដោយគិតទាំងសិក្ខាសាលា កម្មវិធីតុមូល និងវេទិកាផ្សេងៗ អំពីការហាមឃាត់ ផលប៉ះពាល់ និងគ្រោះថ្នាក់ដែលបណ្តាលមកពីអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលអាចផ្សំសម្រាប់ផលិតអាវុធទាំងនេះ ។

**មាត្រា ១៩.-**

ក្រសួងទទួលបន្ទុកវិស័យព័ត៌មាន ត្រូវចូលរួមសហការយ៉ាងសកម្ម ក្នុងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់នេះ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងប្រព័ន្ធផ្សព្វផ្សាយឯកជន ។

## ជំពូកទី ៨
## ការប្រមូលទិន្នន័យ និងការវាយតម្លៃ

**មាត្រា ២០.-**

ទិន្នន័យសម្ងាត់ស្តីពីអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ និងព័ត៌មានសម្ងាត់ដទៃទៀត ដែលផ្តល់ឱ្យ ឬ ទទួលបានស្របតាមច្បាប់នេះ ឬ តាមអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដែលត្រូវបានអនុវត្តតាមរយៈច្បាប់នេះ ត្រូវទុកជាការសម្ងាត់ ។

**មាត្រា ២១.-**

មានតែអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្មទេ ដែលមានសិទ្ធិប្រមូលវាយតម្លៃ និងផ្សព្វផ្សាយអំពីទិន្នន័យ និងព័ត៌មាន អាវុធគីមី អាវុធនុយក្លេ-អ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលពាក់ព័ន្ធនឹងការផលិតអាវុធខាងលើ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩
## មន្ទីរពិសោធន៍ និងស្ថានីយត្រួតពិនិត្យ

**មាត្រា ២២.-**

អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ត្រូវរៀបចំឱ្យមានមន្ទីរពិសោធន៍ និងស្ថានីយត្រួតពិនិត្យអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ នៅតាមទីតាំងដែលសមស្របនិងចាំបាច់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

10/13

**មាត្រា ២៣.–**

ការរៀបចំបណ្តាញស្ថានីយត្រួតពិនិត្យអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ១០
## ការអនុវត្តអនុសញ្ញាអន្តរជាតិ និងសហប្រតិបត្តិការ

**មាត្រា ២៤.–**

បទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិទាំងឡាយណា ដែលទាក់ទងនឹងការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ដែលព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគី ត្រូវយកមកអនុវត្តជាមួយច្បាប់នេះ ។

ករណីមានទំនាស់ជាមួយនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិទាំងនោះ ត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

**មាត្រា ២៥.–**

ព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើសហប្រតិបត្តិការជាមួយអង្គការ ឬ រដ្ឋជាភាគីនៃអនុសញ្ញាអន្តរជាតិនានា ដែលទាក់ទងទៅនឹងការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ដោយឈរលើគោលការណ៍សមភាព និងគោរពអធិបតេយ្យ ស្របតាមអនុសញ្ញាអន្តរជាតិ ។

## ជំពូកទី ១១
## ទោសប្បញ្ញត្តិ

**មាត្រា ២៦.–**

បុគ្គលដែលផលិត កែច្នៃ ទទួល ផ្ទេរ រក្សាទុក ដឹកជញ្ជូនឆ្លងកាត់ ឬ ប្រើប្រាស់ដោយ[illegible]អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

11/13

Ksl

**មាត្រា ២៧.-**

បុគ្គលដែលផលិត កែច្នៃ ទទួល ផ្ទេរ រក្សាទុក ដឹកជញ្ជូនឆ្លងកាត់ ឬ ប្រើប្រាស់សារធាតុគីមីដែលយកទៅផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ២៨.-**

បុគ្គលដែលផលិត ទិញ លក់ កាន់កាប់ កែច្នៃ ទទួល ផ្ទេរ រក្សាទុក ដឹកជញ្ជូនឆ្លងកាត់ ឬ ប្រើប្រាស់សារធាតុគីមីដែលយកទៅប្រើក្នុងវិស័យសុខាភិបាល ឧស្សាហកម្ម រ៉ែ ថាមពល កសិកម្ម និងការស្រាវជ្រាវ ក្នុងគោលដៅសន្តិភាពផ្សេងទៀត ដោយគ្មានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

**មាត្រា ២៩.-**

បុគ្គលដែលបានផ្សព្វផ្សាយព័ត៌មានអំពីទិន្នន័យអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ដោយពុំមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

**មាត្រា ៣០.-**

នីតិបុគ្គល ដែលត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសប្រឆាំងនឹងច្បាប់នេះ ដោយចេតនា ឬ ដោយដឹងខ្លួន ប្រសិនបើខ្លួនបានអនុញ្ញាត ឬ យល់ព្រមដោយផ្ទាល់ ឬ ដោយប្រយោលចំពោះការប្រព្រឹត្តបទល្មើសនោះ ហើយប្រសិនបើនីតិបុគ្គលនោះដែលត្រូវបានសម្រេចឱ្យជាប់ទោសចំពោះបទល្មើសប្រឆាំងនឹងច្បាប់នេះ តុលាការត្រូវកំណត់ពិន័យជាប្រាក់ជំនួសឱ្យរយៈពេលជាប់ពន្ធនាគារ ដោយអនុលោមតាមកថាខណ្ឌខាងក្រោមនេះ :

-ការពិន័យជាប្រាក់សម្រាប់នីតិបុគ្គលគឺ ២.០០០.០០០ (ពីរលាន) រៀល សម្រាប់រយៈពេលជាប់ពន្ធនាគារចំនួន ១២ (ដប់ពីរ) ខែ ដែលតុលាការនឹងដាក់លើនីតិបុគ្គលនោះ ប្រសិនបើនីតិបុគ្គលនោះជារូបវន្តបុគ្គល ។

-បន្ថែមលើការពិន័យជាប្រាក់ តុលាការអាចដាក់ទោសបន្ថែមណាមួយថែម

ទៀត ដូចខាងក្រោម ៖

ក-រំលាយនីតិបុគ្គល ។

ខ-ដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ។

## ជំពូកទី ១២

## អន្តរប្បញ្ញត្តិ

**មាត្រា ៣១.-**

ក្រោយពីច្បាប់នេះ ចូលជាធរមានក្នុងរយៈពេល ៣ (បី) ខែ រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានរក្សាទុកសារធាតុគីមី ទាក់ទងនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលគ្មានលិខិតអនុញ្ញាត ត្រូវមករាយការណ៍ជូន ឬ ប្រគល់ជូនស្ថាប័នមានសមត្ថកិច្ច ។

ករណីមិនផ្តល់ព័ត៌មាន ឬ មិនប្រគល់ជូន ត្រូវផ្តន្ទាទោសតាមជំពូកទី ១១ នៃច្បាប់នេះ ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

**មាត្រា ៣២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

នស/រកម.១២០៩.០២៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

**ហត្ថលេខា**

**ទៀ បាញ់**

លេខ ៖ ៧០៥៨ ច.ល
ការិយាល័យថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឃួង ផឹងកេន

១៣/១៣

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/១០១៩

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** -តែងតាំងឯកឧត្ដម **ឈឹម ភន** ទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី២ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

-តែងតាំងជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី២ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដូចមានរាយនាមខាងក្រោម :

-ឯកឧត្ដម **ភាណុល ទិចិត្រ**

-ឯកឧត្ដម **ជ័យ សុវណ្ណ**

**មាត្រា២:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩១០.១០៤០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩*

លេខៈ ១០៥៧ច.ល
**ជូនដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១០០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- ឯកឧត្តម **មល់ រឿប**
២- ឯកឧត្តម **ហែម សាមិន**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

១- ឯកឧត្តម **ហេង រតនា**
២- ឯកឧត្តម **ឃឹម បូរ**
៣- ឯកឧត្តម **សារ៉ាត់ ខាន់**
៤- ឯកឧត្តម **ឡុង ចិសាលោ**
៥- ឯកឧត្តម **កែច សារផល**
៦- ឯកឧត្តម **ម៉ែន ស៊ីផាន់**
៧- ឯកឧត្តម **ឆាន់ ចឡូន:**
៨- ឯកឧត្តម **កៅ ទ្រី**
៩- ឯកឧត្តម **សៅ សុភខុន**

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ចំពោះ :

១- ឯកឧត្តម **ហ៊ុយ សារ៉ាខុធ**
២- លោកឧកញ៉ា **ប៊ុត ចាន់ធូ**
៣- លោក **ឱត ពិរុណ**
៤- លោក **ហ៊ុយ ហ៊ីន**
៥- លោក **ម៉ម ឡឿន**
៦- ឯកឧត្តម **មាស សុចណ្ណ**
៧- លោក **យន់ សម្បត្តិ**

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១- ឯកឧត្តម **ឌុច សុចណ្ណារី**
២- លោក **ម៉ៅ សាម៉ី**
៣- ឯកឧត្តម **ហាច ប៊ុនសែ**
៤- ឯកឧត្តម **អ៊ាង សុផល្លែត**
៥- លោក **ខ៊ូច បូរីណា**
៦- ឯកឧត្តម **ឯម ម៉ារ៉ូរី**

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៧- លោក ឃួត ឆេ ៨- ឯកឧត្តម ម៉ូល ពិឌូ

៩- លោក ប៊ុន ផេង ១០- ឯកឧត្តម អ៊ិន សាម៉ុន

១១- លោក លឹម គីមនី

ខ.គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ :

- ឯកឧត្តម **ម៉ុត ឆារី**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកត.០៩១១.១១២១

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥*

លេខៈ១០៣០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៥

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ឋិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១១០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

លោក តេរូអូ ជីណាយ

( Teruo JINNAI )

នូវ

## គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ០៩១១. ១១៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩

លេខៈ ១០៣១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ឧនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១១០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ:-

១-ឯកឧត្តម ជា សែ

២-ឯកឧត្តម ម៉ឺន ខេង

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ:-

ឯកឧត្តម ស៊ឹង វ៉ាន់ថន

៣៤.០៩១១.១១៧៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩*

លេខ:១០៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១១០៣

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ:-

១-ឯកឧត្តម នី យឿន    ២-ឯកឧត្តម ឆាយ សាវុធ

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ:-

១-ឯកឧត្តម យាង សេង    ៣-លោក កែវ ធីវុធ

២-លោក ឈុប សាម៉េត    ៤-លោក ហួត ហាក់

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ:-

១-ឯកឧត្តម ម៉ឺន ហុន    ៣-លោក ហេង សុខឃៀង

២-ឯកឧត្តម សរ សម្បត្តិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ:១០៣៣ ច.ល

៣៤៧.០៩១១.១១៧៤

ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជិនកេន

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩*

# ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១១០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

ក.គ្រឿងឥស្សរិយយសជាតូបការ ចំពោះ :

ឯកឧត្តម អ៊ិត សំហេង

ខ.គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១-ឯកឧត្តម សែម សុខា
២-ឯកឧត្តម សយ ស៊ីផុន
៣-ឯកឧត្តម យី យ៉ុន
៤-ឯកឧត្តម សោម ច័ន្ទរ៉ែម

គ.គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្តម ចាប តូនី
២-ឯកឧត្តម ឃួន រ៉ានីន
៣-ឯកឧត្តម ប្រាក់ ចាន់ធឿន
៤-ឯកឧត្តម ខៀវ សុគន្ធ
៥-ឯកឧត្តម សំហេង បូរស
៦-ឯកឧត្តម កែវ បូរេន្ទ្រ
៧-លោក អៀម យាង
៨-លោក តូច ចាន់នី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩១១.១១២៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩

លេខ:១០៣៤ច.ល
[illegible] ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការ [illegible] រាជរដ្ឋាភិបាល
[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៩/១១០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

## កងពលតូចទ័ពពិសេសឆ័ត្រយោង លេខ ៩១១

នូវ

## គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

៣ល.០៩១១.១១២៦

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩

លេខៈ១០៣៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១-ឯកឧត្តម កែវ ពិសិដ្ឋ ២-លោក ស៊ីម សុវណ្ណរិទ្ធិ

ខ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១-ឯកឧត្តម សុខ ឡេង ៣-លោក យស មុនីរ៉ាត់

២-លោក ជៀម សួរ

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១-ព្រះគ្រូនាគមុនីសត្ថាសុខុមោ នី សុវណ្ណមុនីរ័ត ២-ឯកឧត្តម លឹម ប៊ុនសេង

៣-លោក ផាន់ ភឿន

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១-លោកវរសេនីយ៍ទោ ឡោ ប៊ុនហ៊ួយ

ង- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

១-លោកវរសេនីយ៍ឯក ខេន សុវណ្ណ ២-លោកស្រី សាំង រ័ត្នធីតា

ច-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- លោក លី សុខារិរម្យ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ៧.០៩១៥.១១៤៩

លេខ:១០៣៧ ច.ល
ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/00២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដាក់លោកជំទាវ **សុខ ចំនួនធី** បច្ចុប្បន្នជាអគ្គនាយកនៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍសេដ្ឋកិច្ចនៃក្រសួងកិច្ចការនារី ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល ០១ ឆ្នាំ ( មួយឆ្នាំ) លើកទី ១ គិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០០៩ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០១០ ដើម្បីជាផលប្រយោជន៍ផ្ទាល់ខ្លួន ។

ROYAUME DU CAMBODGE – LE MINISTRE DU PALAIS ROYAL

**មាត្រា ២ :** សាមីមន្ត្រីត្រូវតែដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬចូលបំរើការងាររបស់ខ្លួនវិញឱ្យបានពីរខែមុនពេលផុតកំណត់នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ។ បើសាមីមន្ត្រីពុំបានដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬពុំបានចូលបំរើការងាររបស់ខ្លួនវិញនៅថ្ងៃចុងក្រោយនៃភាពទំនេរគ្មានបៀវត្សចាត់ទុកថាបោះបង់ចោលការងារ និងត្រូវបានលុបឈ្មោះពីក្របខ័ណ្ឌពីថ្ងៃនោះតទៅ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*៣រល.០៩១៤.១១៣០*

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩* លេខ:១០៥៧ ច.ល

**ជូនមកដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១០៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ឱ្យចូលនិវត្តន៍តាមក្របខ័ណ្ឌមុខងារសាធារណៈ ដោយនៅរក្សាតួនាទី និងមុខតំណែងក្នុងក្របខ័ណ្ឌនយោបាយរាយនាមដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | | | |
| ១ | **ស៊ឹម សារ៉ាក់** | ប | កើតថ្ងៃទី ០៥-០៤-១៩៥០ | ឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ២ | **មាស សារុន** | ប | កើតថ្ងៃទី ១៥-០១-១៩៥០ | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៣ | **សោម សុគន្ធ** | ប | កើតថ្ងៃទី ០៣-១១-១៩៥០ | ឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| **រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ** | | | | |
| ១ | **អៀម សារុំ** | ប | កើតថ្ងៃទី ០១-០១-១៩៥០ | ឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | | | | |
| ១ | **ម៉ា សុផាន់ណា** | ប | កើតថ្ងៃទី ១៧-០៧-១៩៥០ | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| **ក្រសួងសុខាភិបាល** | | | | |
| ១ | **លឹម ដារាមាណី** | ប | កើតថ្ងៃទី ២២-១២-១៩៥០ | ឧត្តមមន្ត្រី ថ្នាក់លេខ ១ |

**មាត្រា ២ :** ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ឱ្យចូលនិវត្តន៍តាមក្របខ័ណ្ឌមុខងារសាធារណៈ មានរាយនាមដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| **ក្រសួងសុខាភិបាល** | | | | |
| ១ | **យឹត ស៊ុនណារ៉ា** | ប | កើតថ្ងៃទី ១១-១១-១៩៥០ | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ពិសេស ថ្នាក់លេខ ៣ |
| ២ | **គេង សៀន** | ប | កើតថ្ងៃទី ២៩-១១-១៩៥០ | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ពិសេស ថ្នាក់លេខ ៣ |
| ៣ | **[illegible] នីតាន់ណា** | ស | កើតថ្ងៃទី ១១-១១-១៩៥០ | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ពិសេស ថ្នាក់លេខ ៥ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

នស/រកត/១២០៩/១១៣១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៥៤ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១១០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិល ចំនួន **១០ រូប** ក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

សុខាភិបាល គិតចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៨ ដូចមានរាយនាមខាងក្រោម :

| ល.រ | គោត្តនាម និង នាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ |
|---|---|---|---|
| ១ | ហែន បញ្ញា | ប | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ |
| ២ | លឹម ម៉ាលីស | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ |
| ៣ | ហោ ស្រ៊ុន | ប | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ |
| ៤ | ពិច គួច | ប | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ |
| ៥ | សាត់ ម៉ូលីន | ប | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ |
| ៦ | ហ៊ឹម ម៉ារីន | ប | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ |
| ៧ | យួន ឌីណា | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៨ | សេង សុចិន្តា | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៩ | កាន ដាលី | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ១០ | សេង រ័ត្នមុន្នី | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤ |

**មាត្រា ២** : ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិល ចំនួន ០៤ រូប ក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល គិតចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៨ ដូចមានរាយនាមខាងក្រោម :

| ល.រ | គោត្តនាម និង នាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ |
|---|---|---|---|
| ១ | ញ៉ឹម ចល័ក្ខ | ស | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ២ | គី ច័ន្ទផ្កាយង់ | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៣ | ឆន់ មករា | ស | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៤ | ចន ចិតា | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣/ល.០៩១២.១១៣២

លេខៈ១០៥០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ស៊ុន ម្សារ** អត្តលេខ ០២១១០៩ ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ជួយកិច្ចការរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩១២.១១៣៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៥៧ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានផ្ទេរបញ្ចូលទៅក្នុង **ឋានន្តរស័ក្តិ អនុមន្ត្រី** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ២២១ នាក់ ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១ - | លោក **តាន់ ស្វាង** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ២ - | លោក **ពូល សុខតាន់** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ៣ - | លោក **ចាន់ សួង** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ៤ - | លោក **ពេជ្រ ចន្ថា** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ៥ - | លោក **មូ ណារ៉ៃ** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ៦ - | លោក **គីម សារ៉ា** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ៧ - | លោក **ចាន់ សារ៉ាត់** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ៨ - | លោក **គ្រួច សុខជុន** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ៩ - | លោក **សោម ធី** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ១០ - | លោក **សែម ឃីម** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ១១ - | លោក **ញៀម សម្បត្តិ** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |
| ១២ - | លោក **សៅ សារ៉ាត់** | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ១៣ - | លោក ម៉ៀច សាម៉ើ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៤ - | លោក ស៊ុម សុវណ្ណ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៥ - | លោក កែ សេងគីម | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៦ - | លោក សោម តេជៈ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៧ - | លោក យឹម យោន | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៨ - | លោក ញ៉ៀម គីមសាង | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៩ - | លោក ហេង គីមសាន | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ២០ - | លោក មាន់ សារឿន | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ២១ - | លោក មាន់ សារ៉ា | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ២២ - | លោក គង់ ស៊ីផា | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ២៣ - | លោក យ៉ាង គឿន | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ២៤ - | លោក សំ ចាន់ថន | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៥ - | លោក សុត សុខ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៦ - | លោកស្រី ជា ផល្លី | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៧ - | លោក ឆន ភាឌូរ៉ា | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៨ - | លោក ហែន សាគុន | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៩ - | លោក ដួង សោង | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ៣០ - | លោក ខ្លែក ចារី | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ៣១ - | លោក ចាន់ សុខា | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ៣២ - | លោក គុជ សុវណ្ណារី | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ៣៣ - | លោក សេក សំអុល | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ៣៤ - | លោក សេក ហៃ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ៣៥ - | លោក ជុំ តេជា | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ៣៦ - | លោក ឈី ម៉ុំឈ្យ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៩ |
| ៣៧ - | លោក សេង សំអាន | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ៩ |
| ៣៨ - | លោក គង់ ម៉ុងរឿង | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៣៩ - | លោកស្រី ម៉ែក សេដ្ឋា | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៤០ - | លោក ឥន្ទ សើរេដ្ឋ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៤១ - | លោក អ៊ុង ស៊ីថា | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៤២ - | លោក តាំ សារឿន | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៤៣ - | លោក សែម ជារិទ្ធ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៤៤ - | លោក អ៊ុក យ៉ាង | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៤៥ - | លោក សាន ស៊ីចាន់ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៤៦ - | លោក ផែង សុខេម | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៤៧ - | លោក ឌិន ង៉ោ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៤៨ - | លោក មេង សុតា | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៤៩ - | លោក សើ សម្បត្តិ | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៥០ - | លោក ពេញ ជា | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៥១ - | លោក អ៊ិន យុតេង | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៥២ - | លោក ស៊ីទ្ធ គីឈីម | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ៥៣ - | លោក ចាន់ ផល្លី | បានន្តរស័ក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |

| | | |
|---|---|---|
| ៥៤ - | លោក អ៊ិន សំណាង | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១០ |
| ៥៥ - | លោក ឆេស សុខុន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១០ |
| ៥៦ - | លោក សម សំអាត | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ |
| ៥៧ - | លោក សេ៉ វឿន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ |
| ៥៨ - | លោក ចាន់ ធឿន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ |
| ៥៩ - | លោកស្រី អ៊ី សុខណ្ណារ៉ា | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ |
| ៦០ - | លោក ម៉ែ សៅរ៍ | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ |
| ៦១ - | លោក យស់ ឃុល | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ |
| ៦២ - | លោក ម៉ោក គឹមទ្រិក | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ |
| ៦៣ - | លោក ម៉ូន ឈារិទ្ធ | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ |
| ៦៤ - | លោក គីម ពិសី | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ |
| ៦៥ - | លោក អ៊ុម ឆន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ |
| ៦៦ - | លោក សេ៉ សំអួន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៦៧ - | លោកស្រី គីម កញ្ញា | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៦៨ - | លោកស្រី ឧង់ សុឈីណែត | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៦៩ - | លោក កុល បុប្ផា | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៧០ - | លោក ឌុត សោភ័ណ្ឌ | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៧១ - | លោក ស គីមសេង | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៧២ - | លោក កែច យុន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៧៣ - | លោក គន់ ប៊ុណ្ណារី | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៧៤ - | លោក ខែ ហុក | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៧៥ - | លោក សិន យិន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៧៦ - | លោក ម្ហ៉ាំង ឆន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៧៧ - | លោក សៅ សារីម | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៧៨ - | លោក សន គុសល | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៧៩ - | លោកស្រី កុត ប៊ុនធី | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៨០ - | លោក ស៊ាន ផល | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៨១ - | លោក ម៉ៃ សារមេត | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ |
| ៨២ - | លោក ព្រឿន រ៉ាត | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៨៣ - | លោកស្រី អ៊ុច តារា | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៨៤ - | លោក ជា ឈន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៨៥ - | លោក ហន់ មន្ទីរ | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៨៦ - | លោក ស៊ុយ លីន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៨៧ - | លោក សួន សុចាត | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៨៨ - | លោក ឃួត សុនី | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៨៩ - | លោកស្រី ជា សុគន្ធ | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៩០ - | លោក ម៉ុល យុន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៩១ - | លោក ឡា មនោរិទ្ធ | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៩២ - | លោក តឹក គីមចិន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៩៣ - | លោក ម៉ែន សាចិន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ |
| ៩៤ - | លោក ម៉ែន សោភ័ណ | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | |
|---|---|---|---|
| ៩៥ - | លោក | ឈឿន គ្រៃយ៉ុង | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៩៦ - | លោក | ថ្លាង ឆៀង | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៩៧ - | លោក | កេត ចន្ទស៊ុន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៩៨ - | លោក | ទិ ទ៉ា | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៩៩ - | លោកស្រី | ម៉ក់ សុចិមុល | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០០ - | លោក | លី ស្រួយ | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០១ - | លោក | ជួ សុខា | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០២ - | លោក | យឹម និព្វមុនី | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០៣ - | លោក | ចិន ឈួត | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០៤ - | លោក | មៀច សុមន៍ | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០៥ - | លោក | ឆៀន ហេង | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០៦ - | លោក | សៀងឯម សត្យា | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០៧ - | លោកស្រី | មាម មាន់ណារី | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០៨ - | លោក | សែ ជុនត្រី | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០៩ - | លោក | អ៊ាន អេឈើន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១១០ - | លោក | សោម ស៊ិន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១១១ - | លោក | មួន ស៊ាន | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១១២ - | លោក | អ៊ុង ឧត្តី | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១១៣ - | លោក | ភ្លឺ គន្ធី | ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៣១-លោក | ស្រី ហួន | ក្រុមការងារឃុំគគីរ | ថវិកាចំនួន ១.៣៥០ ដុល្លារ |
| ៣២-លោក | សុខ គន្ធា | ក្រុមការងារឃុំត្រពាំងស្តៅ | ថវិកាចំនួន ១.០២៤ ដុល្លារ |
| ៣៣-លោក | រស់ ជា | ក្រុមការងារឃុំសម្បត្តិមានជ័យ | ថវិកាចំនួន ១.៨៥២ ដុល្លារ |
| ៣៤-លោក | ទ្រាវ ឆាត | ក្រុមការងារឃុំសម្បត្តិមានជ័យ | ថវិកាចំនួន ១.៥៤៨ ដុល្លារ |
| ៣៥-លោក | ឡុង សុបិន | ក្រុមការងារឃុំសម្បត្តិមានជ័យ | ថវិកាចំនួន ១.៥២៤ ដុល្លារ |
| ៣៦-លោក | ហ៊ឹម ចាន់ថុន | ក្រុមការងារឃុំអណ្តូងត្របែក | ថវិកាចំនួន ១.៤១២ ដុល្លារ |
| ៣៧-លោក | ម៉ែន ទ៊ែន | ក្រុមការងារឃុំអណ្តូងត្របែក | ថវិកាចំនួន ១.២៤១ ដុល្លារ |
| ៣៨-លោក | ចក់ សាផល | ក្រុមប្រឹក្សាឃុំម្រោម | ថវិកាចំនួន ១.២៤១ ដុល្លារ |
| ៣៩-លោក | ចាន់ ស៊ាច | ក្រុមការងារឃុំម្រោម | ថវិកាចំនួន ១.៣៥០ ដុល្លារ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៦៩៧ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៦ រូប ដែលមានគុណបំណាច់ និងស្នាដៃល្អ ក្នុងការចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋាន នៅខេត្តកំពង់ចាម ក្រចេះ និង ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១- | ឧត្តមសេនីយ៍ទោ | **ឈួន ចាន់រិទ្ធ** | អត្តលេខៈ ០០២៤៤៦ ថវិកា១៥០,៥០០ដុល្លាអាមេរិក |
| ២- | ឯកឧត្តម | **គួន គីមសាយ** | ថវិកា១៥០,៥០០ដុល្លាអាមេរិក |
| ៣- | លោកជំទាវ | **គង ធុន្នា** | ថវិកា១៥,៥០០ដុល្លាអាមេរិក |
| ៤- | លោក | **លីម ចាន់សួគី** | ថវិកា១៥,៥០០ដុល្លាអាមេរិក |
| ៥- | លោក | **ឆឿន ច័ន្ទសុជាតិ** | ថវិកា១៥០,៥០០ដុល្លាអាមេរិក |
| ៦- | លោក | **តាំង សុភាព** | ថវិកា១៥,៥០០ដុល្លាអាមេរិក |

**មាត្រា២:-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៦៩៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:~**

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន ០៦ រូប ដែលមានគុណបំណាច់ និងស្នាដៃល្អ ក្នុងការចូលរួមជួយកសាង អភិវឌ្ឍន៍មូលដ្ឋាន នៅខេត្តកំពង់ចាម ក្រចេះ និង ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | **សរ សម្បត្តិ** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី |
| ២- | ឧកញ៉ា | **លី ឆេង** | សប្បុរសជន |
| ៣- | ឯកឧត្តម | **តូច សុផារ៉ា** | អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ |
| ៤- | វេជ្ជបណ្ឌិត | **តែប គៀតសុហ្វា** | មន្ត្រីក្រសួងសុខាភិបាល |
| ៥- | វេជ្ជបណ្ឌិត | **ឈួប ម៉ួនថន** | មន្ត្រីក្រសួងសុខាភិបាល |
| ៦- | លោក | **ចាន់ បូលណា** | មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ |

**មាត្រា២:~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៦៥៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន ០៦ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន នៅខេត្តកំពង់ចាម ក្រចេះ និង ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១- | លោក | **ពេជ្រ ឡេងគី** | មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ២- | លោកស្រី | **ធឿន ស្វាជាតិទេវី** | សប្បុរសជន នៅរាជធានីភ្នំពេញ |
| ៣- | លោក | **ណុប ឌុធ្ធី** | មន្ត្រីក្រសួងអប់រំយុវជន និងកីឡា |
| ៤- | លោក | **អ៊ុំ ចាន់ណារ៉ែត** | មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ |
| ៥- | លោក | **នៅ សៅ** | សប្បុរសជន |
| ៦- | លោក | **សរ ស្វខណ្ឌរាម** | សប្បុរសជន |

**មាត្រា២:-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ..........អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **ឃិន សុចលក្ខណ៍** ជាអគ្គនាយករង នៃវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៧០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតម្លើងឋានន្តរស័ក្តិ មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ។
- យោងអនុក្រឹត្យលេខ ១៦០៧ អនក្រ.តត ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល
- យោងតាមលិខិតរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

## ស ម្រេ ច

<u>មាត្រា ១</u> : ត្រូវបានតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ពី**អនុមន្ត្រី** ទៅ**វរមន្ត្រី** នៅក្រសួងព្រះបរមរាជវាំង ដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១-លោក | កង | ស៊ីរីសោភ័ណ | ពី **អនុមន្ត្រី** ថ្នាក់លេខ ១១ | ទៅ **វរមន្ត្រី** ថ្នាក់លេខ ១០ |
| ២-លោក | កាន់ | សុវណ្ណា | ពី **អនុមន្ត្រី** ថ្នាក់លេខ ១២ | ទៅ **វរមន្ត្រី** ថ្នាក់លេខ ១០ |
| ៣-លោក | ព្រំ | ពិសុទ្ធ | ពី **អនុមន្ត្រី** ថ្នាក់លេខ ១៣ | ទៅ **វរមន្ត្រី** ថ្នាក់លេខ ១០ |

<u>មាត្រា ២</u> : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៧៧០៧ . អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា១:** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន០២រូប :

១-លោក **ទ៉ា សុផល** ឱ្យបំពេញមុខងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានផែនការ នៃក្រសួងផែនការ

២-លោក **សូ ចណ្ណះ** ឱ្យបំពេញមុខងារ ជាអគ្គាធិការរងនៃអគ្គាធិការដ្ឋាន នៃក្រសួងផែនការ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

PSSD-11/26/2009

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:១៧០៣-អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០០២ ស្តីពីការតម្លើងអធិការដ្ឋាន របស់ក្រសួងបរិស្ថាន ទៅជាអគ្គាធិការដ្ឋាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **អេខ គឹមសាន** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងបរិស្ថាន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា១ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះឱ្យបានសំរេចច្បាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

PSSD

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**១៧០៨ .អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរ និង តែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានផ្ទេរ និង តែងតាំងលោកវរសេនីយ៍ឯក **កែវ តារាពង្ស** អត្តលេខៈ ០១៤៧៥ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម នៃ ក្រសួង មហាផ្ទៃ ថ្នាក់ស្មើប្រធាននាយកដ្ឋាន ។

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ[illegible] ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៧០៥ . អនក្រ.តត**

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា១ :** ត្រូវបានតែងតាំងលោក **យន្ត ឬទ្ធី** ជាទីប្រឹក្សាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៧០.៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន ១៧ រូប ដែលបានលះបង់កំលាំងកាយចិត្ត និង ថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាង សាលារៀន សាលាពុទ្ធិក កុដិ ខ្លោងទ្វារ និង រោងកិត្តិយស នៅ**វត្តឯករាជ្យ** ស្ថិតនៅក្នុងឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ១៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណ **ពេជ សុធីរ** ទីប្រឹក្សាសម្តេចព្រះសង្ឃរាជ **ទេព វង្ស** បច្ច័យចំនួន ១០.៥០០ ដុល្លារ

២-ព្រះតេជគុណ **ឡុច ចំរើន** ព្រះចៅអធិការវត្តឯករាជ្យ បច្ច័យចំនួន ១០.៣០០ ដុល្លារ

៣- ឧបាសក **ទ៊ា ជាង** ប្រធានអាចារ្យវត្តឯករាជ្យ ថវិកាចំនួន ១០.៥០០ ដុល្លារ

៤-លោកវរសេនីយ៍ឯក **សាយ សាគន់** អង្គរក្សសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ថវិកាចំនួន ១០.៤១០ ដុល្លារ

៥-លោក **ហុង សាហ៊ូ** សប្បុរសជនខ្មែររស់នៅប្រទេសអូស្ត្រាលី ថវិកាចំនួន ១០.៤០០ ដុល្លារ

៦- លោក **ម៉ៅ ហ៊ួន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.៣៥០ ដុល្លារ

៧- លោកស្រី ថ័ក់ មុត សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.៣២០ ដុល្លារ

៨- លោកស្រី ឆេព សូនី សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.៣១០ ដុល្លារ

៩- លោក យន្ត អ៊ីន មន្ត្រីគយ និងរដ្ឋាករ ស្រុកស្រែអំបិល ថវិកាចំនួន ១០.៣១០ ដុល្លារ

១០- លោក ផូ ទុន្នី មន្ត្រីគយ និងរដ្ឋាករ ខេត្តកំពត ថវិកាចំនួន ១០.២៥០ ដុល្លារ

១១- លោក ផុន ឈន់ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.២០០ ដុល្លារ

១២- ឧបាសិកា ភន ស៊ាវហៃ សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.២០០ ដុល្លារ

១៣- លោក សំ សឺន ប្រធានការិយាល័យធម្មការ និងសាសនា ស្រុកកំពង់ត្របែក ថវិកាចំនួន ១០.១៨០ ដុល្លារ

១៤- លោក ហា និមល សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.១៧០ ដុល្លារ

**ខ. មេដាយសិរីវឌ្ឍនៈស្ថាបនាជាតិចំនួន ០៣ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណ ម៉ា ហ៊ីម គ្រូសូត្រវត្តឯករាជ្យ បច្ច័យចំនួន ២.២៥០ ដុល្លារ

២-លោកស្រី សុខ សឿន សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២.៤៥០ ដុល្លារ

៣-លោកស្រី ផាន់ ស្រីណុច សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២.៣៥០ ដុល្លារ

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៣៧០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្តល់គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ**ថ្នាក់ **ធិបឌិន្ទ** ផ្តល់ជូនសប្បុរសជនចំនួន ០៣រូប ដែលបានលះបង់កំលាំងកាយចិត្ត និងថវិកាផ្ទាល់ខ្លួនចូលរួមជួយអភិវឌ្ឍន៍មូលដ្ឋាន និងកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា អប់រំ និងសង្គមកិច្ច ស្ថិតនៅក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១-លោក **ខិន តារ៉ា** នាយរងខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តព្រៃវែង

២-លោកវរសេនីយ៍ទោ **អ៊ុំ សាមន** ប្រធានការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

៣-លោកវរសេនីយ៍ទោ **ឌុល អឿន** ប្រធានការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១៧៧៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូនមន្ត្រីរាជការចំនួន ០២ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងថវិកាផ្ទាល់ខ្លួនចូលរួមជួយអភិវឌ្ឍន៍មូលដ្ឋាន និងកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ និងសង្គមកិច្ច ស្ថិតនៅក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១-លោកអនុសេនីយ៍ឯក **នង សារិន** នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

២-លោក **ពេជ្រ ទិត** មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**មាត្រា ២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៧០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនមន្ត្រីរាជការ អង្គការ និងសប្បុរសជនចំនួន ០៨ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងថវិកាផ្ទាល់ខ្លួនចូលរួមជួយអភិវឌ្ឍន៍មូលដ្ឋាន និងកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា អប់រំ និងសង្គមកិច្ច ស្ថិតនៅក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១- លោកស្រីវេជ្ជបណ្ឌិត **ស៊ា សោភ័ណ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៧.៥០០ ដុល្លារ
២- លោកស្រី **ស្រេង ហ៊ុយឆេង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៦.៨០០ ដុល្លារ
៣- លោកស្រី **ម៉ុន ស៊ីណេត** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៦.៥០០ ដុល្លារ
៤- លោក **ហ៊ី សេងឈយន់** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៦.៤៥០ ដុល្លារ
៥- លោក **ខេង ទន់** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៦.១៥០ ដុល្លារ
៦- លោក **ហេង ថៃលី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៥.០៧០ ដុល្លារ
៧- លោក **ថ្លាង រត្នពិសិដ្ឋ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៤.៦០៤ ដុល្លារ
៨- អង្គការ **អូសាគីអ៊ីសរ៉ូតារី** នៅប្រទេសជប៉ុន ថវិកាចំនួន ១២.០០០ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧២០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសសុវត្ថារា** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជននៅក្នុង និងក្រៅប្រទេស ដែលបានលះបង់កំលាំងកាយចិត្ត និងថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាង សាលារៀន សាលាពុទ្ធិកៈ កុដិ ក្លោងទ្វារ និងរោងកិត្តិយស នៅ**វត្តឯករាជ្យ** ស្ថិតក្នុងឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយសុវត្ថារាថ្នាក់ធិបឌិន្ទចំនួន ០៥ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណវិសុទ្ធបញ្ញោ **សំ សារម៉ឿន** គង់នៅសហរដ្ឋអាមេរិក បច្ច័យចំនួន ៧១.២០០ ដុល្លារ
២-លោក **ចាន់ រ៉ាន់** អភិបាល នៃគណៈអភិបាលស្រុកកំពង់ត្របែក
៣-លោកវរសេនីយ៍ឯក **ស ថេង** អនុប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ក្រសួងមហាផ្ទៃ
៤-លោកវរសេនីយ៍ត្រី **ផាន សុខជា** អនុប្រធានការិយាល័យព្រហ្មទណ្ឌ ក្រសួងមហាផ្ទៃ
៥-លោក **អេត សត្យា** ជំនួយការអនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ

**ខ. មេដាយសុវត្ថារាថ្នាក់អស្សប្ញទ្ធិចំនួន ០១ គ្រឿង ផ្តល់ជូន**

លោក **ឯក សម្បត្តិ** មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង

**មាត្រា ២ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧១ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការដំឡើងថ្នាក់តួរសំរុក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| **ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** | | | | |
| ១ | **ឈុង នរិន្ទ** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | | |
| ១ | **អៀង ទេងស៊ុន** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ២ | **អាន សំអុល** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ៣ | **ជៀប ឌុល** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| **ក្រសួងផែនការ** | | | | |
| ១ | **ឃិន សុង** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ២ | **មិច កន្ទុល** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២ :** ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់**ក្រសួងសុខាភិបាល** ដូចមាននាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | **សេក សុខឃឿន** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៥ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧ |

**មាត្រា ៣** : ត្រូវបានដំឡើងថ្នាក់ជូនមន្ត្រីសុខាភិបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់**ក្រសួងសុខាភិបាល** ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៩ នេះតទៅ ដូចមាននាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | **ឡាំ អេងហួរ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧ |
| ២ | **ឯក សុន្ទាឫទ្ធិ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៣ | **សាង សុខុម** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៤ | **គីម ចាន់មុនីន្ទ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៥ | **ឆែ សារិត** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៦ | **ចូន ផល្លា** | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៧ | **ឈិត សុផល** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៨ | **ពៅ ប៊ុនធឿន** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៩ | **កើត ឈុនលី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១០ | **ចក ធីតា** | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១១ | **អ៊ិត ប៊ុនគី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១២ | **តេង ហុកលី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |

| | | | | |
|---|---|---|---|---|
| ១៣ | អ៊ុង សុខ្ខាទី | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៤ | ជួន ចន្ទោភាស | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៥ | ថ្វី ប្រុស | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៦ | អោ អ៊ុច | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៧ | ឆាំ ប៊ុណ្ណារេត | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៨ | សុខ លឹម | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៩ | តា លៀង | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២០ | ទី គៀងហ៊ី | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២១ | ឈ្យូរ សេរីចេតនា | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២២ | តែ ទ៉ាន់ថា | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២៣ | ទ៉ែន ទិត្យ | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |

**មាត្រា ៤ :** ត្រូវបានដំឡើងថ្នាក់ជូនមន្ត្រីរាជការតាមកម្រិតសញ្ញាប័ត្រ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមាននាមខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១ | កែន សម្បត្តិ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |

**មាត្រា ៥ :** មន្ត្រីដែលត្រូវបានដំឡើងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា ៤ ខាងលើ ត្រូវបានរក្សាទុកអតីតភាព សម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពជដែល ។

**មាត្រា ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ មាត្រា ២ មាត្រា ៣ និងមាត្រា ៤ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៧៣.សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង រៀបចំមហោស្រពសិល្បៈចម្រៀងខ្មែរជាសកល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ សម្រាប់រៀបចំមហោស្រពសិល្បៈចម្រៀងខ្មែរជាសកល ដោយបើកទូលាយឱ្យបេក្ខជនចូលរួមពីគ្រប់មជ្ឈដ្ឋាន រួមទាំងអនិកជនខ្មែររស់នៅឯបរទេសផង ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ហ៊ឹម ឆែម** | រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| ២- ឯកឧត្តម | **ពុង ឃាវសែ** | ទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣- ឯកឧត្តម | **ឃឹម សារិទ្ធ** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- លោកជំទាវ | **ម៉ិញ ភុសនី** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៥- ឯកឧត្តម | **អ៊ុក សុជាតិ** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធានអចិន្ត្រៃយ៍ |
| ៦- ឯកឧត្តម | **ឆេព នន្ទរី** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- ឯកឧត្តម | **ជា ប៉េងឈាង** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- ឯកឧត្តម | **ជ័យ ចាប** | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩- ឯកឧត្តម | **សោម សុគន្ធ** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១០- ឯកឧត្តម | **ម៉េង ឃ្លូរ** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១១- ឯកឧត្តម | **សំរឹង កំសាន្ត** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២- ឯកឧត្តម | **ឆឹក់ សុខុម** | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ១៣- ឯកឧត្តម | **សួន ឈាងលី** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៤- ឯកឧត្តម | **ចាន់ គីស៊ីម** | ទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ | សមាជិក |
| ១៥- ឯកឧត្តម | **មាស សារុន** | អគ្គនាយកបច្ចេកទេសវប្បធម៌ | សមាជិករាយការណ៍ |
| ១៦- លោក | **ឆិត ចាវរិទ្ធ** | អគ្គនាយករងទទួលបន្ទុកការងារប្រតិបត្តិ នៃអគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន | សមាជិក |
| ១៧- លោក | **ចំន្ទ សំអាន** | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |

**ប្រការ ២.-**

គណៈកម្មការនេះ មានភារកិច្ចរៀបចំ និងគ្រប់គ្រងដំណើរការមហោស្រពសិល្បៈចម្រៀងខ្មែរជាសកល ដែលនឹងប្រព្រឹត្តទៅក្នុងខែ កក្កដា ឆ្នាំ ២០១០ ឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ ៣.-**

គណៈកម្មការនេះ ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅទីស្តីការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ និងត្រូវបានបង្កើតអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់។

**ប្រការ ៤.-**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រាប់សម្រួលការងារ។

**ប្រការ ៥.-**

សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៦.-**

ថវិកាចំណាយសម្រាប់ដំណើរការមហោស្រពសិល្បៈ បានមកពីចំណូលរបស់សប្បុរសជន និងការរួមចំណែកថវិកាបដិភាគរបស់រដ្ឋ ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អភិបាលរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ៨ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ធនាគារកាណាឌីយ៉ា*
- *អគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន*
- *ដូចប្រការ ៨*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៨៤...ស.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការរៀបចំ និងសម្របសម្រួល «វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣»

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ ១ :-**

ត្រូវបានចាត់តាំងឥស្សរជនជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម ជា «**គណៈដឹកនាំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី៣**» ឱ្យទទួលខុសត្រូវក្នុងការសម្របសម្រួល ការត្រៀមរៀបចំ និងការដឹកនាំ «**វេទិកាលើកទី៣**» នេះ ដែលគ្រោងនឹងប្រព្រឹត្ត នាថ្ងៃទី ០២-០៣ ខែមិថុនា ឆ្នាំ២០១០ ខាងមុខនេះ ÷

- ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជា **ប្រធានវេទិកា**
- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជា **ប្រធានបំរុងវេទិកា**
- ឯកឧត្តម **ឈៀង យ៉ាណារ៉ា** អគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជា **អគ្គលេខាធិការវេទិកា**

**ប្រការ ២ :-**

ក្នុងក្របខ័ណ្ឌនៃការសម្របសម្រួលការត្រៀមរៀបចំនិងដឹកនាំវេទិកាលើកទី៣នេះ **គណៈដឹកនាំវេទិកា** តាមរយៈ **ប្រធានវេទិកា** ត្រូវសហការជាមួយនឹងប្រធាននៃបណ្តាក្រសួង និងស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ ឱ្យចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែងពិគ្រោះយោបល់ជាមួយបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីសម្របសម្រួលការងារ និងដើម្បីរៀបចំសេចក្តីព្រាងឯកសារចាំបាច់ៗនានា ។

**ប្រការ ៣ :-**

**ប្រធានវេទិកា** ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូន **សម្តេច នាយករដ្ឋមន្ត្រី** អំពីវឌ្ឍនភាពនៃការរៀបចំវេទិកាលើកទី៣ និងឯកសារចាំបាច់នានា ដើម្បីដាក់ជូន **សម្តេច នាយករដ្ឋមន្ត្រី** ពិនិត្យផ្តល់អនុសាសន៍ និងអនុម័ត មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

**ប្រការ ៤ :-**

ក្នុងការត្រៀមរៀបចំវេទិកាលើកទី៣ **អគ្គលេខាធិការវេទិកា** ត្រូវរាយការណ៍ជាបន្តបន្ទាប់ពីវឌ្ឍនភាពការងារជូន **ប្រធានវេទិកា** និង **ប្រធានបំរុងវេទិកា** ដោយត្រូវប្រើប្រាស់រចនាសម្ព័ន្ធរបស់គណៈ-កម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ ៥ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងប្រធានវេទិកា ប្រធានបំរុងវេទិកា និងអគ្គលេខាធិការវេទិកា ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៦ :-**

សេចក្តីសម្រេចនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៩

ទីស្តីការគណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី

**សម្តេច អគ្គមហាសេនាបតី តេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
-ដូចប្រការ៥
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៧៥៥..ស.សរ

# សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចការងារ និងចូលរួមបើកការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើក ទី២៥ នៅទីក្រុងវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចាប់ពីថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០០៩ រហូតដល់ពេលសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេស វិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី អភិបាល គ្រប់ខេត្ត និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល :</u>

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ២*

*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ១១.០៤...ឧ.ស.រ.ថ..ប្រក

# ប្រកាស
## ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ
## នៃ នាយកដ្ឋានព័ត៌មាន

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានស្តង់ដារកម្ពុជា
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ ១** : នាយកដ្ឋានព័ត៌មាន ស្ថិតនៅក្រោមការគ្រប់គ្រងនិងដឹកនាំផ្ទាល់របស់វិទ្យាស្ថានស្តង់ដារកម្ពុជា និងមានភារកិច្ចដូចតទៅ :

- គ្រប់គ្រង និង បែងចែកលិខិតចេញ-ចូលរបស់វិទ្យាស្ថាន
- រៀបចំពិធីការក្នុងការទទួលភ្ញៀវ សិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងពិធីផ្សេងៗដែលពាក់ព័ន្ធនឹងការងាររបស់វិទ្យាស្ថាន

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

- គ្រប់គ្រងការងារមន្ត្រីរាជការក្នុងវិទ្យាស្ថាន
- រៀបចំគម្រោងថវិកា និងសហការជាមួយនាយកដ្ឋានជំនាញដើម្បីលើកគម្រោងសុំថវិកានិងសម្ភារៈ បរិក្ខារសម្រាប់បំរើការនៅក្នុងវិទ្យាស្ថាន
- ទទួលបន្ទុកការងារបង់កម្រៃអាជ្ញាប័ណ្ណជូនរដ្ឋ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើបញ្ជីសារពើភ័ណ្ឌរបស់វិទ្យាស្ថាន
- រៀបចំបែបបទ និងនីតិវិធីផ្តល់ និងទទួលព័ត៌មានដែលទាក់ទងនឹងច្បាប់ បទប្បញ្ញត្តិបច្ចេកទេស ស្តង់ដារូបនីយកម្ម ការវាយតម្លៃភាពអនុលោម និងការធានាគុណភាពក្នុងនិងក្រៅប្រទេស
- ទទួលបន្ទុកជាចំណុចកណ្តាលក្នុងការឆ្លើយតបទៅនឹងសំណួរ-ចម្លើយរបស់អតិថិជនឬភាគីពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេស អំពីព័ត៌មានទាក់ទងនឹងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម
- រៀបចំបោះពុម្ព និងផ្សព្វផ្សាយឯកសារស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស ព្រឹត្តិប័ត្រ និងលិខិតផ្សេងៗរបស់វិទ្យាស្ថាន
- គ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគ្រប់គ្រងបណ្ណាល័យរបស់វិទ្យាស្ថាន
- បូកសរុបនិងធ្វើរបាយការណ៍ការងារនិងសកម្មភាពផ្សេងៗរបស់វិទ្យាស្ថាន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានវិទ្យាស្ថានប្រគល់ជូន ។

**ប្រការ ២** : នាយកដ្ឋានព័ត៌មាន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៣** : នាយកដ្ឋានព័ត៌មាន មានរចនាសម្ព័ន្ធដូចតទៅ :

- ការិយាល័យរដ្ឋបាលនិងបុគ្គលិក
- ការិយាល័យព័ត៌មាននិងការងារពាណិជ្ជកម្មពិភពលោក
- បណ្ណាល័យស្តង់ដារ

ការិយាល័យនិមួយៗដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អង្គការលេខរបស់នាយកដ្ឋានព័ត៌មានជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៤** : អំពីតួនាទី និង ភារកិច្ចរបស់ការិយាល័យនិមួយៗ :

១- **ការិយាល័យរដ្ឋបាលនិងបុគ្គលិក :**

**តួនាទី :**

ការិយាល័យរដ្ឋបាលនិងបុគ្គលិក ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការគ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក សន្តិសុខសណ្តាប់ធ្នាប់ និងចំណូល-ចំណាយរបស់វិទ្យាស្ថាន ។

**ភារកិច្ច :**

- គ្រប់គ្រង និងបែងចែកលិខិតចេញ-ចូលរបស់វិទ្យាស្ថាន
- គ្រប់គ្រងការងារមន្ត្រីរាជការក្នុងវិទ្យាស្ថាន
- គ្រប់គ្រង និងត្រួតពិនិត្យការធ្វើចរាចរលិខិត ឯកសារគ្រប់ប្រភេទ ដើម្បីធានាធ្វើជាច្រកចេញចូលតែមួយ
- គ្រប់គ្រងថវិកាចំណូលនិងចំណាយរបស់វិទ្យាស្ថាន
- ទទួលបន្ទុកគ្រប់គ្រងត្រាមូលនិងត្រាឈ្មោះថ្នាក់ដឹកនាំរបស់វិទ្យាស្ថាន
- រៀបចំពិធីការក្នុងការទទួលភ្ញៀវ សិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងពិធីផ្សេងៗដែលពាក់ព័ន្ធនឹងការងាររបស់វិទ្យាស្ថាន
- គ្រប់គ្រងការការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងវិទ្យាស្ថាន
- សហការជាមួយនាយកដ្ឋានជំនាញ ដើម្បីលើកគម្រោងស្នើសុំថវិកា និងចំណាយថវិកាសំរាប់ពិធីបុណ្យជាតិ-អន្តរជាតិ បោះពុម្ពប័ណ្ណ លិខិតគ្រប់ប្រភេទ ទិញសម្ភារៈបរិក្ខារសម្រាប់បម្រើការងារនៅក្នុងវិទ្យាស្ថានតាមការចាំបាច់
- ទទួលបន្ទុកការងារបង់កម្រៃអាជ្ញាប័ណ្ណជូនរដ្ឋ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើបញ្ជីសារពើភ័ណ្ឌរបស់វិទ្យាស្ថាន
- បូកសរុបនិងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់វិទ្យាស្ថាន។

## ២- ការិយាល័យព័ត៌មាននិងការងារពាណិជ្ជកម្មពិភពលោក :

**តួនាទី :**

ការិយាល័យព័ត៌មាននិងការងារពាណិជ្ជកម្មពិភពលោក ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារសេវាព័ត៌មាន និងជាចំណុចផ្តល់និងទទួលព័ត៌មានដែលពាក់ព័ន្ធនឹងការប្រតិបត្តិកិច្ចព្រមព្រៀងស្តីពីការរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម។

**ភារកិច្ច :**

- រៀបចំបែបបទ និងនីតិវិធីផ្តល់និងទទួលព័ត៌មានដែលទាក់ទងនឹងច្បាប់ បទប្បញ្ញត្តិបច្ចេកទេស ស្តង់ដារូបនីយកម្ម ការវាយតម្លៃភាពអនុលោម និងការធានាគុណភាពក្នុងនិងក្រៅប្រទេស
- ទទួលបន្ទុកជាចំណុចកណ្តាលក្នុងការឆ្លើយតបទៅនឹងសំណួរ-ចម្ងល់របស់អតិថិជន ឬភាគីពាក់ព័ន្ធទាំងក្នុងនិងក្រៅប្រទេស អំពីព័ត៌មានទាក់ទងនឹងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម
- ធ្វើជាលេខាធិការរបស់គណៈកម្មការរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ដែលគណៈកម្មការនេះមានភារកិច្ចរៀបចំការងារពាក់ព័ន្ធនឹងការអនុវត្តច្បាប់និងបញ្ញត្តិពាក់ព័ន្ធទាំងឡាយនៅក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ

- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធដល់ការងារស្តង់ដារូបនីយកម្ម ការវាយតម្លៃភាពអនុលោម និងការរកទីផ្សារក្នុងស្រុកនិងក្រៅប្រទេស
